# កម្រងពរជ័យ

ប្រមូល និង រៀបរៀង

ដោយធម្មាចារ្យ ហែម អេម

ជំនួយស្មារតីដល់អ្នកឃោសនា

រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស ២៥៤៤ គ.ស ២០០០

៦១៤.
៣៥ក

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh        www.elibraryofcambodia.org**

៦១៤.១៣៥៩

# អារម្ភកថា

សៀវភៅកម្រងពរជ័យនេះ ជាសៀវភៅមួយសំរាប់ជំនួយដល់អ្នកឃោសនា រឺក៏ អ្នកអោយពរក្នុងកម្មពិធីបុណ្យផ្សេង ៗ ។ ខ្ញុំសង្ឃឹមថា:សៀវភៅនេះនឹងបានជាប្រយោជន៍ដល់សិក្ខាកាមជនទាំងឡាយ ដែលមានបំណងសិក្សាស្រាវជ្រាវនូវអត្ថបទដែលទាក់-ទងទៅ នឹង ការអោយពរជ័យនេះ ។

បុព្វហេតុដែលនាំអោយកើតសៀវភៅនេះឡើង ដោយខ្ញុំយល់ឃើញថា អត្ថបទកម្រងពរជ័យនេះ មិនសូវសំបូរបែប មានការខ្វះខាតច្រើន ដូច្នេះហើយ ទើបខ្ញុំប្រមូលរៀបរៀងចងក្រងជាសៀវភៅនេះឡើង ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក អាចារ្យ ប្រុក ឡូត ដែលបានផ្តល់ អត្ថបទមួយចំនួនដល់ខ្ញុំ និង ភិក្ខុ សាត់ គន្ធី ជាលេខាសិស្សពុទ្ធិកវិទ្យាល័យសម្តេច ជួន ណាត ខេត្តកំពង់ចាម ដែលបានជួយកែសំរួលពាក្យពេចន៍មួយ ចំនួន និង រៀបចំចាត់ចែងបោះពុម្ព ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
០៩០៣/03

ខ្ញុំសូមខន្តីអភ័យទោសផងដែរ អំពីសំណាក់លោកអ្នកចេះដឹងទាំងឡាយ បើសិនមានការខ្វះខាត រឺ មានកំហុសដោយអចេតនា ត្រង់ចំណុចណាមួយ សូមជួយកែតំរង់អោយទានផង ដើម្បីទុកជាសម្បត្តិព្រះពុទ្ធសាសនាតរៀងទៅ ។

ដោយអានុភាព ដែលខ្ញុំបានព្យាយាមរៀបរៀងកម្រងពរជ័យនេះ សូមអោយព្រះពុទ្ធសាសនារុងរឿងជាភិយ្យោភាពរហូតដល់ ៥០០០ ព្រះវស្សា ។



ថ្ងៃទី ២០ ខែ តុលា ព.ស ២៥៤៤ / គ.ស ២០០០

ធម្មាចារ្យ ហែម អែម



# របៀបជូនពរ



## អត្ថបទផ្ដើមឃោសនា

*នមោ នមស្សការព្រមកាយវាចានឹង ចិត្ត តស្ស ដោយចំព្រះទ្រង់-យសដ៏ថ្លៃថ្លា គួរវន្ទព្រះសម្មា ត្រៃលោកាប្រសើរផុត ។ មនុស្សនិង ទេព្ដា ទេពព្រហ្ម នាគពិភព ព្រះជាទីគោរព នឹងជាម្លប់ដ៏ក្សេមក្សាន្ត ។

សម្មាសម្ពុទ្ធស្ស ចំពោះព្រះភគវន្ត ស្ដេចទ្រទ្រង់អនន្តគុណធ្ងន់ សែនសោភា លើសអស់មនុស្ស ទេព្ដាឥន្ទព្រហ្មទីបំផុត ។

ព្រះធម៌ដ៏ថ្លៃថ្លា ពុទ្ធដិកាជាឱសថ ជាថ្នាំប្រសើរបំផុត ជាងឱសថក្នុងពិភព ដែលប្រកបគ្រប់រោគា មានតែព្រះធម៌ថ្លៃ ផ្សះចង្រៃរោគ នានា កិលេសមលា អោយភ្លឺថ្លាជាស្រលះហោង ។

ព្រះសង្ឃអរិយសាវ័ក ទ្រង់ជឿជាក់គ្មានសៅហ្មង ឆ្លងផុតត្រៃលោកផង តាងសាស្នានៃព្រះពុទ្ធ ។

ខ្ញុំម្ចាស់សូមប្រណិបតន៍ សូមលើកឡើងលំអុតគោរព -ក្រោមព្រះបាទ សូមឱវាទ សុភមង្គលដ៏កល់លើសិរសា សូមប្រាជ្ញាដ៏និមល ពាក្យពេចន៍កុំមានទ័ល កុំមានខ្វល់កិច្ចឃោសនា លើកចិត្ត លើកសទ្ធា ញាតិញោមមីងមា ប៊ុ ហ៊ា អ៊ុ អ៊ុម សប្បុរសជនក្នុងបុណ្យកុសលកសាង ក្នុងពិធីបុណ្យដូចតទៅនេះ :

អនុមោទនា !

អនុមោទនា !

អនុមោទនា !

* ទី ១ : សាធុៗ បងមានសទ្ធាជ្រះថ្លា យកអរូបរិក្ខា មកចូលបុណ្យទក្ខិណានុប្បទាន សូមអោយបងបាន មគ្គផល ជូនដល់មាតាបិតា ញាតិកាទាំង ៧ សន្តាន ដែលលោកចែកឋានទៅណាកន្លែងណា សូមផលទានេះ ជូនអោយដល់ដូចសេចក្ដីប្រាថ្នា បើអស់លោកជីដូនជីតា បានទទួលហើយ បែរភក្ត្រ ងាកក្រោយ អោយពរដល់កូនចៅ ដែលនៅរស់នៅក្នុងបច្ចុប្បន្ន អោយបានសុខកាយសប្បាយចិត្ត មានអាយុវែង ។

អនុមោទនា !

* ទី ២ : សាធុ ៗ កុមារា កុមារី នៅវ័យក្មេងសំឡេងពិរោះសម្ដីស្រស់ថ្លា មានបញ្ញាវាងវៃ រៀនសូត្រចាប់ចាំចំណាំបានប្រឡង ប្រជែងជាប់ ចាក់ឌុប ចាក់អង លិស្សង់ លិស្សេរ ជាប់ គ្មានទំនេររៀងរាល់ឆ្នាំ ។

អនុមោទនា !

* ទី ៣ : សាធុ ៗ បងមានសទ្ធាជ្រះថ្លា កាត់កម្លាសាធារណ៍ មាន បច្ច័យបូជា បុណ្យទក្ខិណានុប្បទាន ទេវាគន្ថា និវេទយុំ សូមទេវតា កាមាទិព្វព្រះឱស្ឋទិព្វ ជួយដឹកនាំផលានិសង្ស ទៅជូនមាតាបិតា ដែល លោកបែកកាយរំលាយខន្ធទៅកាន់ភពខាងមុខនោះ អោយបានសំរេច ដូចសេចក្តីប្រាថ្នា ។

អនុមោទនា !

ទី ៤ : សាធុ ៗ ឱម្ចាស់ថ្លៃ ជីដូនអើយ មានសទ្ធា ជ្រះថ្លាណាស់ បានចូលបច្ច័យ ក្នុងកិច្ចបុណ្យ សូមអោយលោកយាយ មានសុខភាព បរិបូរ អាយុយឺនយូរ ជាងរយវស្សា រោគាព្យាធិក្នុងកាយទាំងប៉ុន្មាន អោយសាបរលាបជាសះស្បើយហើយ ពីត្រឹមថ្ងៃហ្នឹងទៅ បើសិនជា មានដូចរោគា សើស្បែកកើតប្រើស ស្រកីអណ្តែង ស្រែងជជុះមាន់ ខ្ទួនបុកខ្ទួនក្រឡឹតប្រស្មិត ឆ្កួតជ្រូក គប់ចាម៉ល់ទល់ពះជោ សូមកុំ អោយមាន អោយមានតែសុខកាយសប្បាយចិត្ត ថ្ងៃ ៨ ថ្ងៃ ពេញបោរ ខែដាច់ សំរេចអុចធូបបីសរសៃ បានសុខចំរើន ។

អនុមោទនា !

* ទី ៥ : សាធុ ៗ បងស្រី ប្អូនស្រី មានសទ្ធាជ្រះថ្លា មានបច្ច័យចូល បុណ្យ សូមអោយទេព្តាគ្រប់ឋាន ជួយប្រសិទ្ធិពរជ័យ សិរីសុខា ប្រកប

ដោយសម្បត្តិ ៣ ប្រការ សម្បត្តិ មនុស្ស និង សម្បត្តិ ទេព្តា សម្បត្តិអស្ចារ្យ គឺ ព្រះនិព្វាន ។

អនុមោទនា !

* សម្បត្តិទី ១ : មាសប្រាក់ កែងកង ត្បូង ពេជ្រ និល កែវពិទូរស្សេរកាន ជាដើម ។

* សម្បត្តិទី ២ : មានហ្វូល ប្រៃ ទេសឯក ជាមួង ចាតី មុយអា ជាមួងទំនើបថ្មី ដាកក្រុង យូឡុង ប្រេវ៉ូញ ប្រេលាត ប្រេដ្ឋា ផុស រលើប រំលេចភ្លឺឆ្លុះសារុង សាច់តេតារ៉ុង ម៉ុងតាគុយ កាណាដា ប៉ូឡូ សាច់ចាក់ ខោអាវ វែងខ្លី អាវសង្គ្រែ ម៉ាត់តាណោ ស្លឹបរ៉ាន់តា ពីក្នុង យូឡុងពីក្រៅ ចាតិៈ សារ៉ុង ។ គោមចង្កៀង មាំងសុង អគ្គិសនី ។ កាណូត កប៉ាល់ ទូក សំពៅ សំប៉ាន បើកបរសីសាន្តគ្រប់ទិសទី ទាំងផ្លូវគោក ផ្លូវជល់ធីរ មូលមីរដេរ ដាស កុំអោយលោកអ្នកនាងខ្វះកន្ទះឡើយ ។

អនុមោទនា !

* ទី ៦ : សាធុ ៗ ឥមិនា បសាទេន លោកបងមានសទ្ធា មាន បច្ច័យចូលបុណ្យ សូមអោយលោកប្រកបដោយសម្បត្តិ៣ ប្រការៈ

* សម្បត្តិទី ១ : សូមលោកបានជួបប្រទះ ជួរអោយក្រាក់ កែងកែង កែវពិទូរស្វរកាន ត្បូង ពេជ្រ និល ជាដើម ។

* សម្បត្តិទី ២ : ហ្វូល ប្រែ តេសឯក ជាមួយ ចាក់ មុយេរ៉ា ជាមួយ ទំនើបថ្មី យាកក្រុង យ្យូរ្យុង ប្រែវ្យូញ ប្រែលោក ប្រែភ្លា ពុស រលើប រំលេចភ្និច្ចះសារុង សាច់គេតារ៉ុង ម៉ុងតាក្រូយេ តាណាយ៉ា ប៉ូក្យូ សាច់ពាក់ ទោរាក់ រ៉េងទ្បី រាវសេង្រ្គុ ម៉ាក់តាឡេ ស្ញ៊ីបរ៉ាង់កា ពិច្ចុង យ្យូរ្យុងពីព្រៃ ពិតិៈ សារ៉ុង ។ គោមចង្កៀង អ៊ុំងស៊ុង អក្ខិសរ ។ កាឡេក កច៉ាល់ ទូក សំពៅ ស៊ីប៉ាន បើកបរស៊ីសៅន្ត្រគ្រប់ទិសទី ទាំងផ្លូវគោក ផ្លូវជល់ធីរ មូលមិរជេរ យាស កុំអោយលោកអ្នកនាងខ្វះខាតឡើយ ។

អកុលោកតា !

* ទី ៧ : សាធុ ៗ ប្អូននារី មុំទរីកបូចផ្កា ក្នុងវេលាព្រឹកព្រហាម អាច ម្ចងចិត្តទីករបើកចំពោះតុលោព្រះរតនត្រ័យ ប៉ប្រសើរផុត ព្រែលោកតា ប្រកបដោយសទ្ធាជ្រះថ្លា បានចូលបច្ច័យថ្វាប់កុសលផលបុណ្យ និងការ ទន់ភ្លន់ សុំក្រាបផ្ទារកគេព្យវាស្នា ពត្តិភ្ជិស្យាង សូមប្អូននារីអាចបញ្ញាព្រះថ្លា រៀនសូត្ររក្សាសាស្ត្រ លេខ តុលាប្អូនតែក បានចារឹត្យាស់ ប្រទុងជាប់ ថ្នាក់ ធ្វើមន្ត្រី ចាងហ្វាង រាជរាជ្ជា ក្រឡាបញ្ជី ទីប្រឹក្សា កុង្សី មេឃុំ មេព្រៃ រាជទូត វដ្តទូត បរទេស សូមគប្រេះសំរេច តាមក្រាថ្នា កើត

ទៅជាតិណា ៗ អោយចេះភាសាជាតិ បរទេស មានភាសាអង់គ្លេស ជាដើម សុខសប្បាយធូរទូលាយក្នុងចិត្ត សម្បូរមិត្ត មិនខ្វះឡើយ ។

អនុមោទនា !

* ទី ៨ : សាធុ ១ លោកយាយមានសទ្ធាជ្រះថ្លា ជានាយកដាស់តឿនចិត្តក្រិះរិះ ផ្ចិតអារម្មណ៍ ក្នុងកុសល ដំកល់បញ្ញាសិប់ភ្ជាប់ នឹងសទ្ធាចិត្ត គឺតបរិចាកប្រាក់កាស់ធ្វើជាទាន តាមកំលាំងធនធាន ឥតវុញភា បើលោកយាយ ធ្វើដំណើរទៅកាន់ទី នានា ពួកមារ សត្រូវចៀសចេញ សូមអោយលោកយាយប្រកបដោយកំលាំង ភោគធន ឥត ខ្វះចាយ អាយុយឺនយូរវែង ឆ្ងាយ ដល់ទៅរយឆ្នាយកុំបីឃ្លាតឡើយ សូមអោយបានសំរេច សម្បត្តិ ៣ ទុក្ខសោករោគភ័យ កុំបីបៀត រហូតដល់បច្ឆិមជាតិ កុំអោយលោកយាយឃ្លាតអំពីព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឡើយ ។

អនុមោទនា !

* ទី ៩ : សាធុ១ចៅប្រុស មានចិត្តសន្តោសផុលផុសក្នុងប្រាណ បានចូលបច្ច័យក្នុងបុណ្យទាន សូមអោយចៅបានសុខ ចំរើនរកស៊ីមានបាន កើតល្អតលាស់ របស់ណាខ្វះ សូមអោយ មានរបស់ណាគ្មាន សូមអោយបានងាយរបស់ណាឆ្ងាយ សូម អោយមកជិត

របស់ណាមិនបានគិត សូមអោយនិម្មិតកើតឯង ៗ ។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

អនុមោទនា !

* ទី ១០ : សាធុ ៗ ចត្តារោ ធម្មា វឌ្ឍន្តិ ពរទាំងឡាយ ៤ ប្រការ ចូរចំរុងចំរើន ដល់ លោកអ្នក ដែលមានសទ្ធាជ្រះថ្លា ។

១ . អាយុវឌ្ឍនាទីឃា វែងឆ្ងាយ រាប់ជាងរយព្រះវស្សា

២ . សម្បុរកាយភ្លឺថ្លា រលើបរលោង ដូចពេជ្ររស្មីទិព្វ រីករាយរលោងស្រិលឥតមានមន្ទិល ស្រមោចវារវិលធ្លាក់ ។

៣ . សុខភាពរាងកាយ នីរទុក្ខ នីរភ័យគ្មានមមែព្រួយលំបាកខ្ជបខ្ជាច អំណាចតក់ស្លុតរន្ធត់ ។ អរោគ្យាព្យាធិ គ្មានរោគាព្យាធិបៀតបៀនឡើយ នាំអោយមានតែសប្បាយចិត្តគ្រប់យ៉ាង ។

អនុមោទនា !

* ទី ១១ : សាធុ ៗ ប្អូនមានសទ្ធាជ្រះថ្លាបានបច្ច័យចាប់ មគ្គផល សូមកុំអោយលោកមានរោគាព្យាធិ មកកាត់ ខ្ទាក់ខ្ទិន ឃ្លង់ដែក ឃ្លង់-ល្មៅ ស្រែង ស្រីស្រកី អណ្តែង ជដុះមាន់ បណ្ឌិត រឹងរៃប្រចាំកាយ បានក្លាយខ្លួន អភិរម្យ សមសោភា សុខសាន្ត សំរាន្ត សប្បាយ ទូលំ-ទូលាយដរាបដល់ ព្រះនិព្វាន ។

អនុមោទន !

* ទី ១២ : សាធុ ៗ ប្អូនជ្រះថ្លាបានបច្ច័យចាប់ មគ្គផល ផ្តល់កំលាំងជួយចាត់ចែងក្នុងពិធីបុណ្យ សូមជូនផលានិសង្ស ទ្វេគុណ ១០០.១០០០ គុណ តាមលំដាប់សំរាប់ប្អូន ដែលមាន សទ្ធាជ្រះថ្លាចំណាយបច្ច័យចាប់មគ្គផល ជួយឧបត្ថម្ភ កម្មវិធី ចាត់ចែងក្នុងពិធីបុណ្យ សូមជូនមគ្គផល ដល់ប្អូន អោយបាន សំរេចផលានិសង្ស ទ្វេឡើងជាសតគុណ សហស្សគុណ សូមទេព្តាចាស់ថ្មី ជាកសិណសាក្សី កុំបីភ្លេចជួយបង្ហូរនូវធនធាន តាំងពីតូចលូតលេច ច្រើនកន្លង សូមអោយមានមហិទ្ធិឫទ្ធ វិជ្ជា ស័ក្តសិទ្ធ ផ្លូវលោក ផ្លូវធម៌ក្នុងព្រះពុទ្ធសាសនា បានជ្រកកោន ក្រោមឆាយា ព្រះបារមីដ៏ធំធេង ផុតផែនដី នៃព្រះពិជិតមារ ទេព្តា ព្រហ្មាជួយជ្រុំជ្រែងសណ្ឋិត ជុំវិញប្រាណ បានថ្កុំថ្កើងរុងរឿងជានិច្ចនិរន្តតវែងទៅ ។

អនុមោទនា !

* ទី ១៣ : សាធុ ៗ អរគុណណាស់លោកយាយមានសទ្ធាជ្រះថ្លាមានចតុបច្ច័យ ចាប់មគ្គផល បុណ្យទក្ខិណានុប្បទាន សូមអោយលោកយាយមានសុខភាពល្អបរិបូរ អោយប្រាសចាករោគាព្យាធិទាំងឡាយ រោគហើមហាល់ ធ្លល់ចុកសៀត ចង្អៀតដើមទ្រូង ឈឺ

មុខចុកក្រោយស្តាំងស្តមរឹងរៃប្រចាំកាយ អោយបានក្លាយទៅជាសុខ
ដល់ព្រះនិព្វាន ។

អនុមោទនា !

* ទី ១៤ : សាធុ ៗ ប្អូនមានសទ្ធាជ្រះថ្លា សូមអោយបានសុខ បាន
ចំរើន អាយុវែងរាប់រយវស្សា អោយរូបល្អដូចនាងវិសាខា អោយមាន
បញ្ញាដូចព្រះមហោសថ តំរេះចេះផុតគ្រប់សាលា ប្រឡងប្រជែងជាប់
ជាសាស្ត្រាចារ្យ ចេះភាសារុស្ស៊ី កូរេ ចិន វៀតណាម ចាម ថ្វា ឥណ្ឌា
ភូមា កាណាដា ប៉ូឡូញ អេស្ប៉ាញ៉ុល បារាំង អាមេរិកាំង អង់គ្លេស
អាឡឺម៉ង់ ។ ល ។

អនុមោទនា !

* ទី ១៥ : សាធុ ៗ បងស្រីមានសទ្ធាជ្រះថ្លា បានបរិច្ចាគធនធាន
មានបច្ច័យចូលបុណ្យ សូមអោយបានសុខចំរើន រកស៊ីមានបានភោគ
សម្បត្តិ តាំងពីសំពត់អាវសាវស្បៃ ផាហ៊ុម បាតី មាសប្រាក់ កែវកង
ពិទូរ្យស្វរិកាណ្ណ លក់ចេញទិញចូល ចំណូលចំណេញ ចំរើនឡើងជា
លំដាប់ តាមប្រាថ្នា បើធ្វើស្រែចំការ អោយបានដើមដង ល្អតលាស់
មានផ្លែផ្កា មិនព្រួយរក្សាគ្រប់ពេលឡើយ ។

អនុមោទនា !

* ទី ១៦ : សាធុ ៗ ចែមានសទ្ធាជ្រះថ្លា ប្រាថ្នាជាពុទ្ធង្កូល បណ្ដូលសារពេជ្រ ចេញពីហទ័យបេះដូង មានបច្ច័យ បរិចាក ចូលបុណ្យ តាមសទ្ធាមុះមុត សូមអោយចែមានតំរេះវិជ្ជាហត្ថកម្ម ខាងផុលចាក់ ចាក់ស្រេះ ក្បូរក្បាច់រចនា ផ្កាត្របែក ផ្កានួនស្រី ផ្កាក្ដាំងរងា ផ្កាចាន្ទន៍ ផ្កាចា ជាគំរូរចនា អោយខេមរាជំនាន់ក្រោយ ដាក់លក់ដូរ អោយគ្រប់អ្នកទិញគ្រប់សាសន៍ មានចារាំង ចិន ចាម ចិន ថ្វា ចំរើនភោគាហៀរហូរតាមសេចក្ដីប្រាថ្នា ។

អនុមោទនា !

* ទី ១៧ : សាធុ ៗ ឥច្ឆិតំ បត្ថិតំ តុម្ហំ ខិប្បមេវ សមិជ្ឈតុ : លោកអ្នកមានសទ្ធាជ្រះថ្លា ជាពុទ្ធង្កូរ បណ្ដូលសារពេជ្ជ សារក សារិកា ពុទ្ធមាតា ពុទ្ធបិតា ឬ ឥដ្ឋមនុញ្ញផល យ៉ាងណា សូមអោយ លោកអ្នកបានសំរេច យ៉ាងនោះ រួសរាន់ទាន់ចិត្ត កុំបីឃ្លាតឃ្លាយទៅ ជាប្រការដទៃឡើយ ។

អនុមោទនា !

* ទី ១៨ : សាធុ ៗ ឱចែចិនខ្មែរ មិនចេះខ្មាស់ មានចិត្ត ប្រកប ដោយសទ្ធាជ្រះថ្លា លះបង់បច្ច័យចូលបុណ្យ សូមអោយចែប្រកប ដោយ សោភ័ណបញ្ចពិធកល្យាណីប្រាំប្រការ ។

ទី ១ . លំអរសក់ កេសា ដូចក្ងោកពង្សាពេញពង់ ។

ទី ២ . លំអរសាច់ស្រេច ហ្មត់ចត់ រិមបរបូរមាត់ទាំងសងខាង ប្រហាមដូចផ្លែចាស់ទុំ ស្រស់ឆ្អិនឆ្អៅ គួរអោយភិរម្យតាំងពីក្រមុំដល់ចាស់ ។

ទី ៣ . លំអរធ្មេញពេញ ធ្មេញ ដូចពេជ្រថ្មៃ ហាសើចប្រិមប្រិយសមសោភ័ណ ទឹកដមភ្លីផ្អែកប្រាលចូលគ្នាដល់ចាស់ជរាមិនបាក់។

ទី ៤ . ឆវិវណ្ណ ស្បែកសម្បុរថ្ងៃ ខាងក្រៅល្អក្រៃល្អិតហ្មត់ចេង រលើបរលោង ភ្លឺចិញ្ចែង រស្មីភ្លឺទែងចាំងឈៀលធ្លាក់ វណ្ណៈដូចពណ៌ផ្កាពិការ សម្ពស្សភ្លឺថ្លា ប្រាសចាក សាទ្បាកមន្ទិលសៅហ្មង ប្រជ្រុយ អាចម៍រុយ សាច់ដុំ កន្ទួល ប៉ិកប៉ោងស្រែងស្រេះប្រេះស្រកា សូម្បីអាយុ ១០០ វស្សា នៅដូចដូចកាយា ១៦ ។

ទី ៥ . លំអរវ័យ សូម្បីប្រសូត្រកូន ម្ដងៗ សាច់ឈាមគ្មានស្រកស្រុតកន្លង អាចថ្មីមប្រឡង នឹង ក្មេងព្រហ្មចារី ។

អនុមោទនា !

* ទី ១៩ : សាធុ ១ លោកតា មានសទ្ធាជ្រះថ្លា ក្នុងកុសល ដំកល់ទុកក្នុងព្រះសាសនា បានសំរេចជាកំណាប់ព្រេងតែងរក្សា អោយរូបលោកតា

បានបរមសុខ ។ ដូច្នេះ សូមបួងសួង គុណកែវរតនទាំង ៣ មាន ឫទ្ធិក្រៃជាប្រមុខ ទុកជួយជារនាំង ពាំងពារក្ដីទុក្ខ ដែលវាឃុំរានរុក ក្នុងរាងកាយ របស់ណាឆ្ងាយ សូមមកជិត របស់ណាមិនបានគិត សូមអោយកើតងាយ បើលោកតាផុតជីវិត ទៅកាន់លោកនាយ សូមអោយជៀសឆ្ងាយអំពី អាបាយទាំងពួង ជរាបព្រះសិរអារ្យមេត្រី ពោធិសត្វថ្លៃ បានចេះមាំមួន នូវធម៌វិន័យ កុំបីស្ងួន បានសំរេច មគ្គ ៤ ផល ៤ ដូចលោក តាប្រាថ្នា ។

អនុមោទនា !

* ទី ២០ : សាធុ ១ មឹងមានចិត្តស្អាតចេង អំពីបាបធម៌ បាន ចូលបច្ច័យដោយស្មោះសរ ទុកជាគ្រឿងល្អ នៃចេតនា សព្វទេវា មហិទ្ធិកា សូមពួកទេវតា មានរិទ្ធទាំងឡាយ ដែលស្ថិតអាស្រ័យ លើដើមរុក្ខា គិរីបព្វតា សូមជួយខ្វល់ខ្វាយគ្រប់គ្រងរក្សា នូវ រូបរាងកាយ បានសុខក្សេមក្សាន្ត ដល់ឋានផុតទុក្ខ ។

អនុមោទនា !

* ទី ២១ : សាធុ ១ ធធម្មាយតនានំ អរិតលោ បើលោកក្រាច រង្គាត់ ក្នុងសំសារវដ្ត ប្រាកដក្នុងព្រះពុទ្ធសាសនា សូមកុំ អោយ មានវិកលវិការ នៃ អាយតនៈ ចក្ខុ សោតៈ កាយៈ ជិវ្ហា មនោ

បរិបូរពេញលេញ ។ សព្វរោគា វិនស្សន្តុសុំកុំអោយកើតរោគ ហឹកហក់ ហើមខ្លួន ឈ្លង់ ឬសម្លុងចាក របេងរីងរៃ ឬ កើតរោគាពាធ ដោយអាប ធ្មប់ ខ្មោច ព្រាយ ចាក់ដោត ឈើ ចុកចាប់ សព្វាងកាយ សូមអោយបរវៀសចៀសចេញឆ្ងាយ កុំបីឃ្លាតឡើយ ។

អនុមោទនា !

* ទី ២២ : សាធុ ១បងស្រី ប្អូនស្រី ប្រពៃណាស់មានសន្តានចិត្តជ្រះថ្លា បានចូលបច្ច័យ កប់ទុកក្នុងព្រះពុទ្ធសាសនា ជាកំណប់បុណ្យប្រសើរក្រៃ ខ្លាចចោរចង្រៃ គឺ ជរា ព្យាធិ មរណៈ ដិតដាមជាប់តាមខ្លួនប្រាណគ្រប់ ៗ គ្នា ធ្វើអោយលំបាក រាល់ពេលវេលា សូមអោយបង ប្រាសចាករោគាព្យាធិ ទាំងឡាយ សូមកុំអោយប៉ះពាល់ ដល់សរីរាង្គកាយឡើយ សូមបានសំរេចដូចសេចក្តីប្រាថ្នា ។

អនុមោទនា !

*ទី ២៣ : សាធុ ៗ សេដ្ឋន្ទទោ សេដ្ឋមុបេត្យិ ឋានំ លោកអ្នក អោយទីឋានដ៏ប្រសើររមែងបាននូវទីឋានដ៏ប្រសើរ ។ អគ្គទាយី វរទាយី លោកអ្នកអោយនូវ វត្ថុដ៏ប្រសើរ រមែងបាននូវវត្ថុដ៏ល្អ ទីឃាយុយស្សវាហោន្តិ . យត្ថយត្ថូបបជ្ជតិ នរជននោះទៅកើត ក្នុងទីណា ៗ រមែងជាអ្នកមានអាយុវែង មានសេចក្តីសុខសាន្តក្នុងទីនោះៗមិនខានឡើយ ។អនុមោទនា !

*ឌី ២៤ : សាធុ ៗ ប្អូនមានសទ្ធាជ្រះថ្លា តាមចិន្តាមយបញ្ញា ត្រិះរិះភ្លឺច្បាស់ សូមអោយប្អូនប្រាសចាក រោគាព្យាធិ ទាំងឡាយ តាំងពីរោគស្គំសក់ ល្អក់ភ្នែក រិលមុខ ខ្យល់ចាប់ អាប់ប្រាជ្ញា កើត រោគាព្រាយក្រឡាភ្លើង ចុកចាប់ដៃជើង អុត កញ្ជ្រិល រោគព្រូនតូច ធំ ប៉ុលកា គេនញ៉ា ម្រេញ មមែ ទាមឡា ស្វាយក្រាប ក្តាមខ្មៀ ហៀរសំបោ ។ល។ សូមអោយបវៀសឆ្ងាយកុំបីសេសសល់ឡើយ។

អនុមោទនា !

* ឌី ២៥ : សាធុ ៗ បងមានសទ្ធាជ្រះថ្លា ប្រកបដោយសុក - មយបញ្ញា បានចូលបច្ច័យចំពោះបុណ្យកុសល ទេវាគន្ធានិវេទឃុំ សូមទេព្តា ជួយបង្ហូរ ផលានិសង្ស ធនធាន កើតកាលបែកគុម្ព ត្រជាក់ត្រជុំ ថ្កុំថ្កើងរុងរឿង ជាណំរាប់ សូមអោយមូលមិត្ត ក្រុម-គ្រួសារ ជីដូនជីតា ស្វាមី ភរិយា សូមអោយលោកឈ្នះមារ សត្រូវ គ្រប់ទិសទី មកពីមុខសូមអោយរំលង មកពីខ្នង សូមអោយ រលាយ បាក់បបខ្ទបខ្ទាចអំណាចផលទានលោកអ្នកបានធ្វើក្នុងថ្ងៃ នេះអោយបានសំរេចដូចសេចក្តីប្រាថ្នា ។

សូមអនុមោទនា !

*ទី ២៦ : សាធុ ៗ បងប្រុសបានចូលបច្ច័យ បណ្តុះនិស្ស័យ ពូជសទ្ធា ក្នុងព្រះពុទ្ធសាសនា សូមគុណបុណ្យព្រះត្រ័យរតនា ទេវតា ឆកាមា ឋិត លើផែនដីព្រៃព្រឹក្សា អាកាសវិហាស៍បពីតគិរី ភ្នំតូចភ្នំធំ សូមគ្រប់មុខ របរ កេណ្ឌផលាទទុងតម្រាស់ពីក្រោម សុទ្ធតែពួកព្រហ្មចៀមចំ កម្រាល មហាសយនា ពីលើសុទ្ធតែមុង ពិតាន ។ ចំហៀងរនាំង វាំងននថៃបែ មាត់ទ្វារ មុខក្រោម សំបូរ សប្បាយ ចាយវាយមិនរលោះ គ្រប់ពេល - វេលា ឡើយ ។

អនុមោទនា !

*ទី ២៧ : សាធុ ៗ លោកគ្រូជាគំរូសិក្ខាកាម បរិបូរដោយវិជ្ជា ចេះ ដឹងនៅវត្តឃ្លា ដឹកនាំកុលបុត្រ-ធីតា សូមប្រាជ្ញាចេះចាំស្ទាត់ មិនមាន ទើស ទាល់អ្វីឡើយ វិជ្ជាចាក់ឧប ចាក់អង លិស្សងត៍ កំប្លែ អោយបាន សំរេច ជា ស្ថាពរ ។

អនុមោទនា !

*ទី ២៨ : សាធុ ៗ អ្នកគ្រូសូមមានបញ្ញា ឆ្លៀសឆ្លាស់វោហារអង់អាច ស្មារតី បរិបូរដោយន័យ បង្ហាត់បង្ហាញជៀសវាង ស្មុគ្រស្មាញ តុញតុះ គំនិតស្ទាត់ខាងវប្បធម៌ អក្សរ លេខនព្វន្ត នយោបាយគ្រប់គ្រាន់ល្អក្រៃ កន្លងអស់ទាំងសិស្ស គ្រសង ខំរៀនយល់តាមប្រសើរពេកក្តាត់ គ្រប់សិស្ស

ទាំងអស់ ឥតមានអសប្បុរសចំពោះ អ្នកគ្រូឡើយ ។

អនុមោទនា !

*ទី ២៩ : សាធុ ៗ លោកយាយមានសទ្ធាជ្រះថ្លាប្រពៃណាស់ សូមអោយលោកយាយ បានឈ្នះលើពិការ វង្វេង មានចិត្តស្អាតផង បានចូលបច្ច័យ ប្រាថ្នាយកគុណបុណ្យឧបនិស្ស័យ សូមគោរព ជូនពរផលដីម្ចាស់ថ្លៃ សូមអោយវ័យថ្មោងថ្មីដូច កាលនៅពីក្មេង ធមីអាចីកុំអោយវង្វេងអាយុ សូមអោយបានវែងតទៅ ។

អនុមោទនា !

*ទី ៣០ : សាធុ ៗ ជូនអ្នកសីនសៃ ប៊ុកណេង ឈាហុកជាវ ពរហាំង យុគី ប្រែភាសាខ្មែរ អោយចិក បានសុខ បានចំរើន រកស៊ី មានភោគសម្បត្តិ សំបូរកូនប្រុស កុំអោយដាច់សៃ ។

អនុមោទនា !

*ទី ៣១ : សាធុ ៗ បងមានសទ្ធាជ្រះថ្លា បានលះមច្ឆរិយៈ គឺសេចក្តីកំណាញ់ស្វិតស្វាញ ជឿជាក់ក្នុងព្រះពុទ្ធសាសនា បានចូលបច្ច័យកប់ទុកជីកដាំផ្កាំភ្ញាស់ បណ្តុះសទ្ធា សូមអោយបងបានជួបសម្បត្តិសុខ សម្បត្តិសួគ៌ សម្បត្តិនិព្វាន ជាស្ថាពរ ។

អនុមោទនា !

*ទី ៣២ : សាធុ ១ ប្អូនមានសទ្ធាជ្រះថ្លា បង្អោនកាយវាចា បានចូលបច្ច័យ ក្រេបផញ្ញក់យកបុណ្យ បណ្តុះសច្ចំ ខន្តី មេត្តា ករុណា ជាដើមទុនអំណត់អត់ធន់ មន្តស្នេហ៍ បុណ្យក្អេក ជាខ្លឹមធម៌ ចិត្តស្លូតស្មោះសរ ដូចព្រះនាគសែន បានសុខាផលាចំរើន ។

អនុមោទនា !

*ទី ៣៣ : សាធុ ១ថែមានសទ្ធាជ្រះថ្លា បានរួមចំណែកចូលបុណ្យសុន្ទរទាន ផលានិសង្សនេះ ជូនដល់ ជីដូនជីតា កុង ម៉ា ប៉ា ប៉េ អ៊ុ·អ៊ីម ស៊ីមសោ ថៃ ចឹក ទ្រា ហ៊ា គួ កូវ អនិច្ចកម្មទៅកាន់លោកខាងមុខក្តី នៅរស់ក្តីសូមអោយទទួលយកបុណ្យ ពីកូនចៅ ហើយបែរភ័ក្ត្រ ងាកក្រោយ អោយពរបវរថ្លៃថ្លា ដល់បុត្តធីតា រស់នៅក្នុងបច្ចុប្បន្ន ប្រកបរបរខាងលក់ដូរអីវ៉ាអីវ៉ាន់ ចាប់ហួយ តែស្ករ ប៊ីចេង ប្រេងឥន្ធនៈ ម្រេច ខ្ទឹម ញញឹមទុកលក់ដាច់ថ្ងៃយប់ ដូចសេចក្តីប្រាថ្នា ។

អនុមោទនា !

*ទី ៣៤ : សាធុ ១ លោកយាយមានបសាទសទ្ធាជ្រះថ្លា មានបច្ច័យចូលបុណ្យ សូមអោយលោកយាយបានសុខគ្រប់ប្រការ សុខតាំងពីផ្លូវប្រុសស្រី កូនខ្ចី កូនប្រសារ កុង ម៉ា តាយាយ យាយទួត ចៅ ចៅលួតចៅលា កំព្រាអត់ម្តាយ មេម៉ាយអត់ប្រពន្ធ-ប្តី សុខទាំងយប់ ទាំងថ្ងៃដូចសេចក្តីប្រាថ្នា ។

អនុមោទនា !

*ទី ៣៥ : សាធុ ១ លោកយាយ មានបសាទសទ្ធាជ្រះថ្លាមាន បច្ច័យចូលបុណ្យ សូមអោយលោកយាយ បានសុខ បានចំរើន កើន រាល់ថ្ងៃ ចង្រៃចេញទៅ សុខសាន្តក្រាណ ចូលមកនៅ រក្សារូបកាយ អោយបានសុខកាយ សប្បាយចិត្ត គ្រប់ពេលវេលា សូមអោយបាន អាយុវែង ។

អនុមោទនា !

*ទី ៣៦ : សាធុ ១បងមានសទ្ធាជ្រះថ្លា មានបច្ច័យចូលបុណ្យ សូមអោយរៀមច្បង បានសុខគ្រប់ប្រការទី១ ដំកល់ទុកក្នុងព្រះពុទ្ធ សាសនា ទី២ ឧទ្ទិសជូនដល់មាតាបិតា ទី៣ ជូនដល់ ទីប្រឹក្សារៀ ទី៤ ទទួលយកផ្ទាល់ខ្លួន សូមអោយបានសុខចំរើន អាយុវែង ។

អនុមោទនា !

*ទី ៣៧ : សាធុ ១ ប្អូនមានសទ្ធាជ្រះថ្លា ដោយមនោសព្ចេតនា មានបច្ច័យចូលបុណ្យ សុន្ទរទាន សូមទេវតា ចាស់ថ្មី ប្រសិទ្ធិពរជ័យ អោយមានធន់បាន ភស្តុភារទ្រព្យឥតខ្វះ គ្រប់ ១ ជាតិ កុំអោយប្អូន ឃ្លាតពីព្រះពុទ្ធឡើយ ។

អនុមោទនា !

*ទី ៣៨ : សាធុ ១ធំមានសទ្ធាជ្រះថ្លា មានបច្ច័យចូលបុណ្យ ទេវាគគ្គានិវេទឃ្មុំ សូមបុព្វទេវតា ជួយផ្សព្វផ្សាយដំណឹងបុណ្យ

នេះ ដល់ ឧបការីជន មាន មាតា បិតា ជាដើម សូមលោកមានគុណ បែរបិត្ត បែរអារម្មណ៍ ទទួលយកបុណ្យយកកុសល ដែលកូនចៅ ឧទ្ទិស ជូនអោយបានសំរេចដូចសេចក្ដីប្រាថ្នា ។

អនុមោទនា !

*ទី ៣៩ : សាធុ ១ បងស្រី ប្អូនស្រី មានសទ្ធាជ្រះថ្លា ប្រពៃមាន បច្ច័យ ចូលក្នុងបុណ្យទក្ខិណានុប្បទាន សូមអោយបងប្អូន បានសុខ បានចំរើន ម្យ៉ាងទៀត ភាគផលនេះ សូមបានជូនមាតាបិតា ទាំង ៧ សន្ដាន ដែលលោកចែកឋានទៅកាន់ទីណា ១ សូមផលទាននេះ ជូន អោយដល់ដូចសេចក្ដីប្រាថ្នា ។

អនុមោទនា !

*ទី ៤០ : សាធុ១ចែមានសទ្ធាជ្រះថ្លា បានចូលបច្ច័យចំពោះស្មោះក្នុង បុណ្យកុសល សូមអោយចែបានសុខចំរើនរកស៊ីមានបាន សម្បត្តិ ប្រើប្រាស់មិនខ្វាត់ តាំងពុ ទូ សាឡុង កៅអី ម៉ាស៊ីនស្រូវ ម៉ាស៊ីនដេរ ម៉ាញ៉េ វិទ្យុ តូចធំគ្រប់ម៉ាក ដាក់តាំងលើតុ ទូ ព័រ ហម្មិការ ភ្លឺថ្លាផ្ទះមុខ ស្រូវអង្ករពេញជង្រុក ឥតខ្វះអ្វី ប្រហុក ផ្អក មាំ ប្រចាំរាល់ថ្ងៃ ត្រីងៀត ត្រីឆ្អើរល្អប្រពៃ ត្រីខប្រអប់ កញ្ចប់បីចេង ប្រេងសណ្ដែក ដី ម្រេចខ្ទឹមស

ក្រឡទឹកត្រី ហេប៊ី តាំងចាយ ស៊ីអ៊ីរ ម៉ាក្ស៊ី ការីតាំងហ៊ុន សំបូរ គ្រប់ធុនឥតខ្វះអ្វី ។

អនុមោទនា !

*ទី ៤១ : សាធុ ៗ បងមានសទ្ធាជ្រះថ្លា មានបច្ច័យចូលចាប់មគ្គផល សូមអោយបានសុខសប្បាយ ចំរុងចំរើន ម្យ៉ាងទៀតជូនដល់ មាតា បិតា អនិច្ចកម្មទៅកាន់លោកខាងមុខក្តី នៅរស់ក្តី សូមអោយលោកទទួលយកបុណ្យកុសលអំពីកូនចៅឧទ្ទិសជូនតាមផ្លូវ កុសល និង មហាកុសល ហើយបែរភ័ក្ត្រ ងាកក្រោយ អោយពរ បង្ហូរជលចាក់ ទំលាក់ចុះសុះសព្ទសាយ កូនចៅជិតឆ្ងាយ អោយបានសុខកាយសប្បាយចិត្ត អាយុជីវិតវែងឆ្ងាយកុំបីឃ្លាតឡើយ ។

អនុមោទនា !

*ទី ៤២ : សាធុ ៗ អ៊ុ ថៃ មានចិត្តចេតនាប្រាថ្នាបុណ្យ សូមអោយថៃ បានប្រកបដោយ បញ្ចពិធកល្យាណី ជាមិត្តមេត្រីល្អ ៥ ប្រការ គឺ ១_ឆវីវណ្ណា សម្បុរសដូចផ្កាស ដូចផ្កាមន្ទាបុស្សខៀវស ដូចត្រយចេក សក្រហម ដូចលោហៈ ទង់ដែង ២_មំសា សាច់ដុំជិតស្និទ្ធហ្មត់ផង់ រអិលព្រិលធូលី ឥតមាន កន្ទឺះ កន្ទួលអាចម៍រុយ

ប្រជ្រុយស្អាតចេង ហាប់ថ្លា ។ ៣ . កេសា សក់ខ្មៅរលោង ដូចត្រោកឥតមានស្កូវ ទង់វែង រហូតដល់ស្លាប់ ។ ៤.អដ្ឋិ ធ្មេញលំអរច្រេញ សស្អាត ដូចផ្កាកគេច្នៃ ដំរិមត្រឹម គ្មានច្របេសច្របុសដរាបដល់ស្លាប់ ។ ៥ . អាយុលំអរ មានវ័យវឌ្ឍនាការ ១២០ ឆ្នាំ នៅមានសភាពដូចក្មេងអាយុ១៦ឆ្នាំ មិនពិការឡើយ ។

អនុមោទនា !

* ទី ៤៣ : សាធុ ៗ ក្មួយមានសទ្ធាជ្រះថ្លា មានបច្ច័យចូលបុណ្យ សូមអោយក្មួយមានវិជ្ជា ចេះស្ទាត់គ្រប់គ្នាខាងសិប្បកម្ម ចេះធ្វើការនាឡិកាខ្នាតូចខ្នាធំ ជួសជុលចាស់ថ្មី ទោះខូចគ្រឿងអ្វី ធ្វើបានទាំងអស់ ឥតមានទើសឥតមានទាស់ ទាល់ចំណេះឡើយ ។

អនុមោទនា !

*ទី ៤៤ : សាធុ ៗ ឥទំ នោ ទានំ ផលទាន របស់លោកអ្នក ដែលមានសទ្ធាជ្រះថ្លា ហើយ អាចញ៉ាំងប្រយោជន៍អោយសំរេច បាន ដូចគោលបំណង ប៉ងប្រាថ្នាទោះបីមានដំណើរទៅកាន់ទីណា ឈ្នះសត្រូវគ្រប់ទិសទី

អនុមោទនា !

*ទី ៤៥ : សាធុ ៗ ប្អូនមានសទ្ធាជ្រះថ្លា ចិត្តជឿជាក់កុសលផលជួយ

BUDDHIST INSTITUTE LIBRARY

រក្សាផុតក្តីទុក្ខ លំបាកវេទនា ផលជួយអោយ សុខ ចំរើនគ្រប់វេលា ប្រាសចាករោគា ភ័យផងទាំងឡាយ ។

អនុមោទនា !

*ទី ៤៦ : សាធុ ៗ តេជៈជយោ្យ សូមអោយសម្បូរកបកល់តេជៈ បារមី សិរីសួស្តី វិបុលសុខ ផុតទុក្ខទាំងអស់ ដូចសេចក្តីប្រាថ្នា ។

អនុមោទនា !

*ទី ៤៧ : សាធុ ៗ ចែមានសទ្ធាជ្រះថ្លា បានចូលបុណ្យ សូមនឹកផលគុណ កែវទាំងបី គឺ កែវ គឺ ព្រះពុទ្ធ កែវ គឺ ព្រះធម៌ កែវ គឺ ព្រះសង្ឃ លោកជួយកំចាត់បង់ សេចក្តីសៅហ្មង សូមអោយសំបូរមាសប្រាក់ កែវកង ហូរចូលគឹកកង ទាំងយប់ទាំងថ្ងៃ ។

អនុមោទនា !

*ទី ៤៨ : សាធុ ៗ ប្អូនប្រុសមានសទ្ធាជ្រះថ្លាសត្យស ចិត្តស្មោះនិង បុណ្យ សូមអោយមានស្មារតី វៃយប្រសព្វ ចំណេះចេះចប់ ខាងលេខនព្វន្ត គុណចែក សង ហា ឃើញភ្លាម ៗ ប្រាជ្ញាចេះចាំបាន ។

អនុមោទនា !

*ទី ៤៩ : សាធុ ៗ ប្អូនស្រីបានចូលរួមភ្ជាប់និស្ស័យសទ្ធា សូម

អោយមានវិជ្ជា ខាង ផុលចាក់  ចាក់ស្រែះ ស្មូរក្សាច់ រំលេចស្មូរក្សាច់ របនាបូជា ផ្កាត្របែក ផ្កានួនស្រី ផ្កាក្តាំងារ ផ្កាចន្ទន៍ ផ្កាចារ ផ្កាក្រោក ម្លិះលា ព្រលិត រំចង់ ស្បង់ជ ចំប៉ី ស្រឡី ចំប៉ា ចេះដូច ប្រាថ្នា កុំបីឃ្លៀងឃ្លាតឡើយ ។ អនុមោទនា !

*ទី ៥០ : សាធុ ១ ប្អូនស្រីមានសទ្ធាជ្រះថ្លា សូមអោយប្អូនប្រកបមុខ របរខាងជាងកាត់ដេរ ចេះស្ទាត់ខ្នាតកាត់វាស់ ចាន់រាងចាន់រីក ឃើញមុខ អោយនឹក ឃើញកាត់អោយត្រូវ តាំងពីចំហៀង ត្រង់ គ្រប់ម៉ូត គ្រប់ម៉ាក ទាំងអស់ឥតខ្វះអ្វី ។ អនុមោទនា !

* ទី ៥១ : សាធុ ១ ក្មួយ ១ កុមារា ចំឡើងកាលណាដុះគំនិត ដុះចិត្ត រៀនសាលា សូមអោយមានបញ្ញាចេះភាសា បរទេស បារាំងសេស ចិន ជប៉ុន អាមេរិកាំង ចេះខ្លាំងជាងគេកម្ពុជា ។ អនុមោទនា !

* ទី ៥២ : សាធុ ១ ប្អូនមានសទ្ធាជ្រះថ្លា សូមអោយប្អូនមានគំរេះ ចំណេះចំណាំ ចេះចាំធ្វើពេជ្រ ធ្វើត្បូង ចេះចាំ រំលេខចិញ្ចៀន ខ្សែ ដៃ តាំងពីខ្សែក បន្តោងពេជ្រ ត្បូង ច្រវ៉ាក់ចាប ថ្ងៃ នូវ ត្បូងចំហៀង ផ្លែ កន្ទុក ផ្កាថ្កូវ ផ្កានគោង ផ្កា ក្តុល ចេះធ្វើជូសជុល ដូចចេញពីហាង ។

អនុមោទនា !

* ទី ៥៣ : សាធុ ៗ សុវណ្ណវណ្ណោ រូបរាងពណ៌ សម្បុរកាយ ក្លាយដូចមាសទឹកដប់ ក្លិនកាយសាយសព្វដូចផ្កាចំប៉ា អញ្ជើញទៅណា សូមទេវតាជួយអោយបានជោគជ័យ សិរីសួស្តីគ្រប់ប្រការ អាយុយឺនយូរវែង ដូចប្រាថ្នា ។ អនុមោទនា !

* ទី ៥៤ : សាធុៗលោកយាយមានសទ្ធាជ្រះថ្លា ប្រាថ្នាយករូបបុណ្យ រូបកុសល ដំកល់ ទុកក្នុងថ្នត់ ដក់អារម្មណ៍ ស្តាប់ស័ព្ទធម៌ សំដែងទុក ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប ដរាបគ្រប់ជាតិ កុំអោយយាយឃ្លាតពីព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃឡើយ ។

អនុមោទនា !

* ទី ៥៥ : សាធុ ៗ លោកយាយមានសទ្ធាជ្រះថ្លា ជឿជាក់ ជឿចំ ជឿមាំ ជឿឥតករេ្រីក សូមអោយលោកយាយ ជាប់ធម៌ ៣ សច្ចំ ខន្តី កតញ្ញូ វិន័យគ្រប់គ្រាន់ ទាន់ព្រះសរិអារ្យមេត្រីពោធិសត្វ ថ្ងៃ បានស្តាប់ធម៌អំពីព្រះឱស្ឋទិព្វ បានសំរេច មគ្គផល ដល់ព្រះនិព្វានហោង ។

អនុមោទនា !

* ទី ៥៦ : សាធុ ៗ សុខិតា ហោថ សហសព្វេហិ ញាតីភិ អ្នកនាងកញ្ញា មានបញ្ញាសទ្ធាជិតស្និទ្ធ ឥតមានចិត្តកាប់បន្ទា ដាក់-

បន្ទាយ កាយ ប្រឡោះ ចិត្តត្រង់ស្មោះ ចំពោះព្រះពុទ្ធជា មកុដលោក សំដែងទុកមក សុខោ បុញ្ញស្សឧច្ចយោ អ្នកនាងសន្សំ នូវ បុណ្យ តែង នាំមក នូវសេចក្ដីសុខចំរើនគ្រប់ប្រការ ឥតទុក្ខព្រួយ ចារម្មណ៍ឡើយ ។

អនុមោទនា !

* ទី ៥៧ : សាធុ ៗ សិរីអាយុ ច វណ្ណោ ចភោគំ សូមអោយបងមាន កំលាំងសទ្ធា អាយុវែង ពណ៌សម្បុរល្អ កំលាំងបញ្ញា ថ្លា គំនិត ប្រមូល ភោគទ្រព្យ ដូចសេចក្ដីប្រាថ្នា ។

អនុមោទនា !

* ទី ៥៨ : សាធុ ៗ បងមានសទ្ធាជ្រះថ្លា សូមអោយបងប្រកបដោយ ពុទ្ធពរ ៤ ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ ។ អាយុ : សូមអោយមាន អាយុវែង វណ្ណៈ : សូមអោយមានពណ៌សម្បុរកាយល្អ សុខៈ : សូម អោយបងបាន សុខកាយ សប្បាយចិត្ត ពលៈ : សូមអោយបងបានប្រកប ដោយកំលាំងកាយ កំលាំងប្រាជ្ញាបាធីក្នុងបសាទសទ្ធា និង សូមអោយ គំរិះប្រាជ្ញាវាងវៃ ចេះច្នៃប្រឌិត ផ្ចិត អារម្មណ៍ ក្នុងច្បាប់ផ្លូវលោក និង ផ្លូវធម៌ ។ ប្រកបដោយបញ្ញាញាណជាលោកិយ និង លោកុត្តរ កុំបី ឃ្លាតឡើយ ។ អនុមោទនា !

* ធី ៥៩ : សាធុ ៗ ប្អូនប្រុស ប្អូនស្រី មានបសាទសទ្ធាជ្រះ ថ្លា ដុះដាលប្រពៃ ក្នុងកាយចិត្ត វាស់វែងគ្រប់ ឥតអស់ កាយ សុំកុំអោយឆ្ងាយអំពីព្រះកន្ធោងព្រះពុទ្ធ បញ្ញាមោះមុត គ្មាន ទើសទ័ល ចេះចាំធម៌អាថ៌ ប្រាកដ ជាប់សីលបរិសុទ្ធ រំលត់ទុក្ខ សោក រោគ ភ័យ បានសុខ ទាំងយប់ទាំងថ្ងៃ ដូចសេចក្តីប្រាថ្នា ។

អនុមោទនា !

* ធី ៦០ : សាធុ ៗ ម្តាយមីងមានសទ្ធាជ្រះថ្លា បានចូលបច្ច័យ ចាប់មគ្គផល សូមម្តាយបានគ្រេបជញ្ជាក់ យកបុណ្យ ផ្តល់ទុន ទុកក្នុងហទយបេះដូងខ្លួន ដល់ថ្ងៃណាសង្ខារសូន្យ បានបុណ្យនេះជូនជាញាតិមិត្ត ធ្វើដំណើរទៅរកស្ថានបរមសុខ ដូចសេចក្តីប្រាថ្នា ។

អនុមោទនា !

* ធី ៦១ : សាធុ ៗ លោកតាមានសទ្ធាជ្រះថ្លា ចូលរួមមានបច្ច័យចាប់មគ្គផល ដំកល់ទុកក្នុងព្រះសាសនា ព្រះពុទ្ធ សូមទេព្តាទិសទាំង ៨ បូព៌ា អគ្នេយ៍ ទក្សិណ និរតី បស្ចិម ពាយ័ព្យ ឧត្តរ ឥសាន្ត ទេព្តា អាកាស ភូមិស្ថានប្រោសព្រំប្រសិទ្ធិពរបវរសួស្តី សូមលោកតាបានសំរេច សម្បត្តិ ទាំង ៣ គឺ សម្បត្តិមនុស្ស សម្បត-

LIBRARY
BUDDHIST INSTITUTE

ទេព្តា និង សម្បត្តិព្រះនិព្វាន ក្នុងញាណបញ្ញា ជាអាវុធ សំរាប់កាប់ផ្តារ បណ្តាញកិលេសតណ្ហា ទាំង ១.៥០០ ក្នុងខន្ធសន្តាន បរិសុទ្ធផុតភ្លើងទុក្ខ ភ្លើងកិលេស កុំបីឃ្លាតឡើយ ។

អនុមោទនា !

* ទី ៦២ : សាធុ ៗ បងប្អូនស្រី ជានារី មានលក្ខិណាជ្រះថ្លា បាន ឧទ្ទិសផ្សាយ នឹង ជូនចំពោះ គ្រូឧជ្ឈាយាចារ្យ មាតា បិតា ដោយ កតញ្ញូតាចិត្ត បើលោក ទទួលហើយ សូមបែរភ័ក្ត្រ ងាកក្រោយ អោយពរអោយជ័យសិរីមង្គល វិបុលសុខ ដល់នាង ជាសិស្សានុសិស្ស រស់នៅក្នុងបច្ចុប្បន្ន អោយសុខសប្បាយ រកស៊ីមានបាន ប្រកប អាយុវែង ។

អនុមោទនា !

*ទី ៦៣ : សាធុ ៗ បងប្អូននារីជាទីប្រពៃ មានប្រជាប្រិយណាស់ ស្រឡាស់ចិត្ត ផ្ចិតអារម្មណ៍ ប្រកបដោយសទ្ធាជ្រោសព្រំក្នុងក្រអៅបេះដូង គ្រេបជញ្ជក់ស្រូបយកបុណ្យកុសល ដំកល់ទុកក្នុងឱរ៉ា សូមទេព្តា ព្រហ្មាព្រះឥន្ទ្រា ចតុលោកបាល ទេព្តារក្សាលោកចាស់ថ្មី ជួយប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការ យំ យំ ឥច្ឆិតំ សមិជ្ឈតុ អ្នកនាងតាំងចិត្ត ប្រាថ្នា យ៉ាងណា១ សូមអោយបានសំរេច យ៉ាងនោះ ១ កុំបីឃ្លាតឡើយ ។

អនុមោទនា !

* ទី ៦៤ : សាធុ ៗ លោកតា លោកយាយ ព្រឹទ្ធាចារ្យ ចាស់ស្រុក ធ្លាប់មានសទ្ធាចាស់ក្លាណាស់ បានលះចតុប្បច្ច័យ ចូលចាប់មគ្គផល សូមអោយលោកតា លោកយាយ ប្រកបដោយព្រះជន្មាយុវែង នឹង ប្រកបដោយសរណគមន៍ ជាទីពឹងទៅក្នុងខាងលោកមុខ គឺព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ក្នុងព្រះពុទ្ធសាសនា បេះធម៌អាថ៌ក្នុងក្រៅ ឋរាបដល់បានសំរេចព្រះអរហត្ត កាត់កិលេស ជាសមុច្ឆេទបហាន បានបរមសុខ កុំបីឃ្លាតឡើយ ។

អនុមោទនា !

* ទី ៦៥ : សាធុ ៗ ម្ដាយធំ ម្ដាយមីង មានសទ្ធាជ្រះថ្លា ចូលចាប់មគ្គផល ក្នុងមហាកុសលថ្ងៃនេះ សូមសម្បត្តិមនុស្ស ១ សម្បត្តិទេវ្ដា ១ សម្បត្តិព្រះនិព្វាន ១ ជាសម្បត្តិ អាស្ចារ្យ ឆ្លងសំសារវដ្តនេះ កុំបីឃ្លាតឡើយ ។ អនុមោទនា !

*ទី ៦៦ : សាធុ ៗ ម្ដាយមីងខ្ញុំមានសទ្ធាជ្រះថ្លា ណាស់ សូមជូនពរ ម្ដាយមីងប្រកបការសិក្សារៀនសូត្រ ធម៌អាថ៌ ស្រវាស្រទេញបំពេញកិច្ចការ កសិកម្ម ពាណិជ្ជកម្មអោយបានកើនចំរើនល្អណាស់ ក្នុងជីវភាព សំបូររុងរឿង ប្រកបដោយព្រះជន្មវែងទៅអនាគតកុំបីឃ្លាតឡើយ ។ អនុមោទនា !

* ទី ៦៧ : សាធុ ៗ ប្អូនមានបសាទសទ្ធាជ្រះថ្លា មានបច្ច័យ ចូលបុណ្យ សូមប្រមូលមហាកុសលរាសីទាំងអស់នេះ ចែកជូនដល់ ប្អូន ដែលមានសទ្ធាជ្រះថ្លា សូមប្រកបដោយពរ មហាប្រសើរ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កើតមានឥតអាក់ខាន កុំបីឃ្លាតឡើយ ។

អនុមោទនា !

* ទី ៦៨ : សាធុ ៗ បងមានសទ្ធាជ្រះថ្លា មានបច្ច័យចូលបុណ្យ សូមប្រមូលបុណ្យកុសលរាសី តេជៈបារមី ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជួយទ្រទ្រង់គាំពារ រារាំង សត្រូវជិតឆ្ងាយ កុំអោយជិតដល់ លោកអ្នកមានសទ្ធា បានសុខចំរើន អាយុវែង ។

អនុមោទនា !

* ទី ៦៩ : សាធុ ៗ បងស្រី-ប្រុស ប្អូនប្រុស-ស្រី មានប្រជាប្រិយ មុខញញឹមស្រស់ សម្ផស្សថ្លា ចិញ្ចើមស្រាយ រីករាយសប្បាយ ចូលបច្ច័យភ្ជាប់ និស្ស័យ ក្នុងព្រះពុទ្ធសាសនា ល្អប្រពៃណាស់ សូមបងប្អូនប្រុសស្រី ប្រកបដោយសម្បត្តិ សម្បូរ ឥស្សរ្យសក្តិ ទ្រព្យហូរចូលឥតអាក់ មួលកូនប្រពន្ធ ទ្រព្យសម្បត្តិចាយ វាយមិនខ្វាក់ សុខចិត្ត សុខកាយ អាយុវែង។

អនុមោទនា !

* ទី ៧០ : សាធុ ៗ ប្អូនមានសទ្ធាជ្រះថ្លា មានបច្ច័យរួមចំណែក ចូល

ចាប់មគ្គផល ក្នុងបុណ្យទក្ខិណានុប្បទាន ខ្ញុំសូមឧទ្ទិសផ្សាយជូន ចំពោះ លោកអ្នកមានគុណទាំងឡាយ មាន មាតា បិតា ជាដើម អស់លោកអនិច្ចកម្មទៅកាន់លោកខាងមុខក្តី នៅរស់ក្នុងបច្ចុប្បន្នក្តី សូមអោយ លោកទទួលយកបុណ្យកុសល ដែលកូនចៅឧទ្ទិសជូន បើលោកទទួលហើយ សូមបែរភ័ក្ត្រងាយក្រោយ អោយពរ មេត្តា សន្តោស ប្រោសប្រណី ដល់កូនចៅប្រុស-ស្រី អោយបានសុខកាយ សប្បាយចិត្ត រកស៊ីមានបាន អាយុវែង ។

អនុមោទនា !

* ទី ៧១ : សាធុ ៗ ក្មួយស្រី សំដីទន់ លើដៃប្រណម្យក្រពុំផ្កា ជ្រះថ្លាបរិសុទ្ធ បញ្ញាមុត ចូលបច្ច័យ ភ្ជាប់និស្ស័យក្នុងបុណ្យ សូមជូនពរក្មួយអោយបានសុខបានចំរើន បើរកស៊ីជំនួញ អោយបានចំណេញ ធ្វើស្រែចំការវិញ អោយបានផលច្រើន បើរៀនសូត្រច្រើន សូមអោយរៀនចេះចាំ វគ្គឃ្លាមុខវិជ្ជា តាមថ្នាក់ អក្ខរទេព្វគុណហា ពេលប្រឡងកាលណា អោយបានជាប់តាមបំណង ។

អនុមោទនា !

* ទី ៧២ : សាធុ ៗ អភិវាទនសីលិស្សនិច្ចំ វុឌ្ឍាបចាយិនោ ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ សូមជូនពរ ៤ ប្រការ

គឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ បានចំរើនកើនកបងល់ អស់លោកដែលមានសទ្ធា ឱនកាយថ្វាយអភិវាទ ព្រះត្រៃរ័ត្ន គោរពម៉ត់ចត់ចំពោះពួកចាស់ទាំងឡាយ មានចាស់ដោយវ័យជាដើម ។

អនុមោទនា !

* ទី ៧៣ : សាធុ ៗ ប្អូនមានសទ្ធាចាស់ភ្លា ហើយ ទីយាយុកា ហោកុសាវេយ្យថ បុញ្ញាំ សូមប្អូនប្រកបដោយអាយុវែងមានបុណ្យព្រេងហូរចូលឥតអាក់ ព្រមទាំងប្រកបដោយ សម្បត្តិ ៣ ប្រការ គឺ សម្បត្តិ មនុស្សសម្បត្តិ ទេព្តា សម្បត្តិ ថ្ងៃថ្លា គឺ ព្រះនិព្វាន ។

អនុមោទនា !

* ទី ៧៤ : សាធុ ៗ លោកយាយ មានសទ្ធាជ្រះថ្លា មានបច្ច័យ ចូលបុណ្យ សូមអោយលោកយាយ ប្រកបដោយអភ័យឯកសិទ្ធ ក្នុងវដ្តសំសារផុតចាក ជរា ព្យាធិ មរណៈ ពោលគឺ ព្រះនិព្វាន ។

អនុមោទនា !

* ទី ៧៥ : សាធុ ៗ ប្អូនមានសទ្ធាជ្រះថ្លា សូមអោយប្អូនកបកល់សំបូរប្រដាប់ប្រដារ បណ្ណាការ តុបតែងខ្លួន ក្រមួនយ៉ាដក់ ក្រាសកញ្ចក់ ថ្នាំលាបសក់ ក្រចក ម្សៅសាប៊ូប្រអូប ក្របួបដាក់ប្រាក់ គ្រប់ថត គ្រប់ថ្នាក់តាំងពី ១ រៀល ទល់ដល់សែនកោដិ ។ អនុមោទនា !

* ទី ៧៦ : សាធុ ១ ប្អូនមានសទ្ធាជ្រះថ្លា មានបច្ច័យចូលបុណ្យ សូមអោយប្អូន បានសុខចំរើន រកស៊ីមានបាន សំបូរហូរហៀរ ពោធ ប្លែក កង់ ម៉ូតូ ស៊ីក្លូ ឡាន ទូកសំពៅ កំប៉ៅ សំប៉ាន បើកបរ កំសាន្តគ្រប់ទិសគ្រប់ទី ផ្លូវគោក ផ្លូវជលធី មូលមិរបេរមាស់កុំអោយ ប្អូនខ្វះ ខន្ទះឡើយ ។

អនុមោទនា !

* ទី ៧៧ : សាធុ ១ ក្មួយកូនខ្មែរ មិនចេះខ្មាស់ មានសទ្ធាណាស់ បានចូលបុណ្យទាន ទុកជាស្ពាន យានជំនិះ ជិះកាត់ចំលងឆ្លងអោយ ផុតទុក្ខ ទាំង ១២ កង សោយកន្លងដល់ព្រះនិព្វាន .... ។

អនុមោទនា !

* ទី ៧៨ : សាធុ ១ ប្អូនមានសទ្ធាជ្រះថ្លា មានបច្ច័យចូលបុណ្យ ល្អប្រពៃ បានជោគជ័យ គ្រប់ប្រការ កើតមានសម្បត្តិ អស្ចារ្យ ពពួក ទេព្តា អោយពរជ័យ មួយឆាកជីវិតប្អូន សូមអោយជួបតែអារម្មណ៍ ល្អប្រពៃសុខសែនបវរឥតថ្នឹមបី ឧបសគ្គចង្រៃ គ្រោះថ្នាក់ភ្លូចចំ ប្រមូលផ្ដុំអោយវិនាសខ្ចាត់ខ្ចាយ ប្អូនស្រលាញ់បុណ្យមិនច្បុត លើក ស្ទួយអោយផុតពីវេទនា ជាតិនេះ ជាតិក្រោយ សុខដូចគ្នា ព្រះពុទ្ធ ទាទា ថា ឆ្លងផុតនូវត្រៃភពគឺ :ព្រះនិព្វាន ។ អនុមោទនា !

* ទី ៧៩ : សាធុ ១ លោកយាយព្រីទ្ធាឧបាសិកា បញ្ញាឆ្លាត សង្ហាត រក
ធមី មានបច្ច័យអង្គរ ចូលចាប់មគ្គផល សូមជូនលោកយាយ បានសេចក្តី
សុខ សេចក្តីចំរើន តរៀងទៅកុំបីឃ្លាតឡើយ ។

អនុមោទនា !

* ទី ៨០ : សាធុ ១ លោកយាយ មានសទ្ធាចាស់ក្លា បញ្ញាឆ្លាត សង្ហាក
ចូលបុណ្យ ជាទុនក្នុងជាតិនេះ និង ជាតិក្រោយ ធ្វើបុណ្យញយ ១ បាន
ភោគសម្បត្តិច្រើន រូបល្អ អាយុវែង ។

អនុមោទនា !

* ទី ៨១ : សាធុ ១ លោកយាយ មានសទ្ធាជ្រះថ្លា ប្រពៃពិតគិតស្រេច
សំរេចចិត្តផ្ចិតអារម្មណ៍ ដឹកនាំបច្ច័យ ទាំងឡាយបូន រៀបចំខ្លួន អោយ
ស្អាត សង្ហាតចូលបុណ្យ សូមគុណតេជៈ ទានបារមី ទេព្តាចាស់ថ្មី ប្រុស
ស្រី កំលោះក្រមុំ ហិចហោះ ចុះមកប្រជុំអោយពរ អោយជ័យ សិរីសុខា
ប្រាថ្នាយ៉ាងណា សូមអោយបានសំរេច ។

អនុមោទនា !

* ទី ៨២ : សាធុ ១ ក្មួយកុមារ ម៉ាក់. ប៉ា អោយបច្ច័យមកចូលបុណ្យ
តាមបញ្ញាឆ្លាត សង្ហាតត្រូវ ពូ ជូនពរ អោយរៀនសូត្រចាប់ចេះតរេះល្អ
គ្រប់វិស័យចាប់ចាំ បំណាំបាន មិនភាន់ច្រឡំ ប្រឡងជាប់ពីថ្នាក់បឋមភូមិ

រហូតថ្នាក់មធ្យម ផ្ទោះត្រឹមឧត្តមភូមិ ឧបកុំប្លេ ជាប់គ្នាន ទំនេរ រាល់ ១ ឆ្នាំ ជាប្រចាំមិនឃ្លាតឡើយ ។

អនុមោទនា !

* ទី ៨៣ : សាធុ ១ កុមារី នៅវ័យក្មេង សំឡេងពិរោះ សម្ផស្ស ថ្លា បញ្ញាឆ្លាត សិក្សារៀនសូត្រ ឆាប់ចាំ ចំណាំបាន ប្រឡងជាប់ ៧ បូក ៣ ៨ បូក ២ ទីបញ្ចប់ តំរេះចេះគ្រប់ផប់ គ្រប់សាលាប្រឡង កាលណា បានដុកទ័រគ្រប់វិស័យ ។

អនុមោទនា !

* ទី ៨៤ : សាធុ ១ ក្មួយ កុមារ មាតា បិតា ទូន្មាន អោយមាន បច្ច័យ ចូលបុណ្យ សូមអោយក្មួយ កុមារ មានវ័យរៀនសូត្រឆាប់ ចាំ ចំណាំបាន ប្រឡងជាប់ គ្រប់ថ្នាក់ តាមវិជ្ជាគ្រូដាក់ទៅតាមក្បួន ចេះចាំក្នុងខ្លួន ឥតគេបន្លំបាន ។

អនុមោទនា !

* ទី ៨៥ : សាធុ ១ ចៅកុមារ បញ្ញាឆ្លាត សង្វាតរៀនសូត្រ ប្រឡងជាប់រហូត ពីថ្នាក់ទាបរហូតថ្នាក់ខ្ពស់ កេរ្តិ៍ឈ្មោះពិរោះ ពី អេះល្បី ប្រឡងធ្វើមន្ត្រី ចាងហ្វាង រាជអាជ្ញា ក្រឡាបញ្ជី ទីប្រឹក្សា ឬ កុង្ស៊ី មេគយ មេព្រៃ រាជទូត បរទេស សូមបានសំរេចដូចប្រាថ្នា

កើតទៅជាតិណា ៗ កូនចៅត្រកូលស្អកស្អម្ភ គំនិតហាម់ខែងរែង ប្រាជ្ញា សីលធម៌ ដុះឯង ៗ នឹងចេះភាសាបរទេស មានអង់គ្លេស ជាដើម មិនខ្វះខាតឡើយ ។

អនុមោទនា !

* ទី ៨៦ : សាធុ ៗ ក្មួយកុមារមាឌវង្សាអស្ចារ្យ បានចូលបច្ច័យក្នុងមហាកុសលដ៏ប្រសើរ សូមទេព្តា ចាស់ថ្មី ប្រសិទ្ធិពរ ជ័យ សិរីសុខា អោយក្មួយកុមារ រៀនសូត្រចាំ ចំណាំបាន ប្រឡងជាប់ ជាសាស្ត្រាចារ្យ ចេះចាំ ភាសាបរទេស តាំងពី អាឡឺម៉ង់ បារាំងសេស អង់គ្លេស អ៊ីរ៉ាក់ អ៊ីរ៉ង់ បង់ក្លាដេស ហុងគ្រី រ៉ូមមានី ថៃឡង់ ភូមា ឡាវ កុំបីរារាក់ខានឡើយ ។

អនុមោទនា !

* ទី ៨៧ : សាធុ ៗ ក្មួយកុមារា កុមារី កូនខ្មែរពូកែសំជី រៀនសូត្រស្ទាត់ដៃ អាស្រ័យនឹងភ្នែក វប្បធម៌ចេះឯកលេខគុណ លេខចែក រំលែកសព្វ បាក់អង បាក់ឱប ប្រឡងមិនយូរ បានធ្វើជាគ្រូសិក្សា ក្មួយមានដំណើរទៅណា មកណា គំរេះប្រាជ្ញាតាមជាប់ជានិច្ច ។

អនុមោទនា !

* ទី ៨៨ : សាធុ ៗ លោកតា លោកយាយ មានសទ្ធាជ្រះថ្លា បាន

ចូលបច្ច័យកសាង ដំកល់ទុកក្នុងព្រះពុទ្ធសាសនា សូមជូនពរលោកតា លោកយាយ កើតទៅជាតិ ណា ៗ មានកំលាំង បញ្ញា ឈ្លៀសវៃ ចេះចាំគម្ពីរបាលី គ្រប់គ្រាន់ ធមី ៨ ម៉ឺន ៤ ពាន់ គ្រាន់តែមើល ចាំ ចំណាំបាន ដូចសេចក្តីប្រាថ្នា ។ អនុមោទនា !

* ទី ៨៩ : សាធុ ៗ លោកអ្នកម្ចាស់ទាន មានសទ្ធាជ្រះថ្លាមាន អដ្ឋបរិក្ខា ចូលចាប់មគ្គផល បុណ្យ ទក្ខិណានុប្បទាន ខ្ញុំ សូមឧទ្ទិស ផ្សាយជូន ចំពោះលោកអ្នកមានគុណ ដែលអនិច្ចកម្មទៅកាន់លោក ខាងមុខក្តី ឬ អស់លោកនៅមានជីវិត រស់នៅសព្វថ្ងៃនេះក្តី សូម អោយលោកទទួល អនុមោទនាយកបុណ្យ យកកុសល ហើយផ្សព្វ ផ្សាយពរជ័យ មកដល់ កូនចៅ នៅក្នុងបច្ចុប្បន្ន បានសុខកាយ សប្បាយចិត្ត រកស៊ីមានបាន អាយុវែង ។ អនុមោទនា !

* ទី ៩០ : សាធុ ៗ បងមានសទ្ធាជ្រះថ្លាបញ្ញាត្រូវតំរូវចិត្ត ផ្ចិត អារម្មណ៍ បាននាំនូវបច្ច័យចូលបុណ្យត្រូវបានខែចិត្ត គំនិត កែខៃបញ្ញា អោយជ្រៅក្នុងព្រះពុទ្ធសាសនាតាមត្រៃវិស័យ របស់ខ្លួន តាមវាស្នាកុំ តវាព្រហ្មលិខិត កុំអន់ចិត្ត នឹងសំណាងយើងស្អាងទុកឡើយបងប្រាថ្នា យ៉ាងណាៗសូមអោយសំរេចយ៉ាងនោះ ៗ កុំបីអាក់ខានឡើយ ។

អនុមោទនា !